**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៨ សលខ

# សារលិខិតជូនពរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
## នៃព្រះរាជាណាចក្រកម្ពុជា
## នៅក្នុងឱកាសពិធីចម្រើនជន្មាយុគម្រប់៧២ឆ្នាំ ឈានចូល៧៣ឆ្នាំ

**សម្តេចអគ្គមហាសេនាបតីតេជោប្រធានព្រឹទ្ធសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់**

នៅក្នុងឱកាសដ៏មង្គលាភិរម្យប្រសើរថ្លៃថ្លាប្រកបដោយសេចក្តីសោមនស្សរីករាយនៃពិធីចម្រើនជន្មាយុគម្រប់៧២ឆ្នាំ ឈានចូល៧៣ឆ្នាំរបស់ សម្តេចអគ្គមហាសេនាបតីតេជោប្រធានព្រឹទ្ធសភា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ខាងមុខនេះ តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីរាជការទូទាំងប្រទេស កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងក្នុងនាមរូបខ្ញុំផ្ទាល់ ព្រមទាំងភរិយា សូមសម្តែងនូវសេចក្តីសោមនស្សរីករាយនិងអំណរសាទរយ៉ាងក្រៃលែង និងសូមគោរពជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការ គោរពជូនចំពោះ សម្តេចអគ្គមហាសេនាបតីតេជោប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សូមសមប្រកបដោយបញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ កាយពលរឹងមាំខ្លាំងក្លា សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ដើម្បីដឹកនាំព្រឹទ្ធសភា ដែលជាស្ថាប័ននីតិប្បញ្ញត្តិកំពូលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវស្នាដៃថ្មីៗធំធេងបន្ថែមទៀតក្នុងការចូលរួមដំណើរការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស ការពង្រឹងសមត្ថភាពស្ថាប័ន និងការកសាងសមិទ្ធផលសង្គមជាច្រើន ដើម្បីវឌ្ឍនភាពសង្គមកាន់តែរីកចម្រើនរុងរឿងខ្លាំងក្លា សំដៅលើកកម្ពស់កិត្យានុភាពជាតិ សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរថែមទៀត។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតប្រកបដោយកតញ្ញុតាធម៌និងកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុតចំពោះ សម្តេចតេជោប្រធានព្រឹទ្ធសភា ដែលកាលនៅជាប្រមុខរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងបទពិសោធប្រកបដោយគតិបណ្ឌិតដ៏មហស្ចារ្យក្នុងការដឹកនាំកម្ពុជា ទទួលបាននូវសុខសន្តិភាពពេញលេញលើផ្ទៃប្រទេស ឯកភាពជាតិ បូរណភាពទឹកដី ស្ថិរភាពនយោបាយ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដែលជាបុព្វបទដ៏សំខាន់ក្នុងការអភិវឌ្ឍនិងការកែទម្រង់រដ្ឋស៊ីជម្រៅលើគ្រប់វិស័យប្រកបដោយភាពស៊ីចង្វាក់គ្នា ដែលមានអភិបាលកិច្ចល្អជាស្នូលដ៏រឹងមាំ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅលើកកម្ពស់កិត្យានុភាពជាតិ ការថែរក្សាសុខសន្តិភាពឱ្យបានស្ថិតស្ថេរគង់វង្ស ការលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ សម្តេចតេជោ បានបន្សល់ទុកជូនថ្នាក់ដឹកនាំជំនាន់ក្រោយ នូវស្នាដៃដែលជាគំរូវីរភាពសំខាន់ៗ រួមមាន ការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ការស្វែងរក និងការចាក់

វ៉ាក់សាំងជូនប្រជាជននៅទូទាំងប្រទេស ការបន្សាំប្រជាជនជាមួយនឹងការរស់នៅក្នុងគន្លងថ្មី ការបញ្ចៀសបាននូវហានិភ័យសង្គមដែលបង្កឡើងដោយវិបត្តិជំងឺកូវីដ-១៩ ការប្រកាសបើកប្រទេស បើកសេដ្ឋកិច្ចសង្គម និងបើកវិស័យទេសចរណ៍ឡើងវិញ ការធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ និងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងការដឹកនាំនិងអំពាវនាវដល់ជនរួមជាតិយើងទាំងក្នុងនិងក្រៅប្រទេសឱ្យចូលរួមចំណែកក្នុងយុទ្ធនាការបំផ្លាញចោលគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ឈានទៅបញ្ចប់សោកនាដកម្មលើទឹកដីដ៏កម្សត់របស់យើង នៅត្រឹមឆ្នាំ២០២៥ និងជួយប្រជាជនដែលជួបប្រទះនូវឧបទ្ទវហេតុគ្រោះមហន្តរាយនានា។ ជាពិសេស ការធ្វើជាប្រធានអាស៊ានប្តូរវេននាចុងឆ្នាំ២០២២ ប្រកបដោយបទពិសោធចាស់ទុំ មានទេពកោសល្យខ្ពស់ក្នុងការដឹកនាំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០និងលើកទី៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធដែលធ្វើឡើងដោយផ្ទាល់នៅកម្ពុជា បានដំណើរការទៅយ៉ាងរលូនទទួលបានលទ្ធផលផ្លែផ្កាជាប្រវត្តិសាស្ត្រ។ ការរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ បានបិទបញ្ចប់ប្រកបដោយជោគជ័យយ៉ាងធំធេង។ ជាងនេះទៀត **សម្តេចតេជោប្រធានព្រឹទ្ធសភា** បានផ្តួចផ្តើមបង្កើតគម្រោងព្រែកជីកហ្វូណនតេជោ ជាព្រែកជីកប្រវត្តិសាស្ត្រលើកទី១ នៅកម្ពុជាដែលនឹងផ្តល់អត្ថប្រយោជន៍ដ៏មហាសាលដល់ប្រទេសកម្ពុជា ជាពិសេស វិស័យដឹកជញ្ជូន អាចកាត់បន្ថយថ្លៃដឹកជញ្ជូនកាត់បន្ថយពេលវេលា កាត់បន្ថយការខូចខាតផ្លូវថ្នល់ ការកកស្ទះចរាចរណ៍ គ្រោះថ្នាក់ចរាចរណ៍ ក៏ដូចជាកាត់បន្ថយនីតិវិធីសម្រាប់នាវា និងបែបបទក្នុងការឆ្លងកាត់ទំនិញពីកម្ពុជាទៅសមុទ្រ ការបង្កើតតំបន់ពាណិជ្ជកម្ម តំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍផែរណបថ្មីៗជាច្រើន ការពង្រីកតំបន់អភិវឌ្ឍន៍កសិកម្ម ធារាសាស្ត្រ វារីវប្បកម្ម ទេសចរណ៍ ជួយរំដោះទឹកជំនន់ក្នុងរដូវវស្សា ជួយបង្កើនផលត្រីទឹកសាបតាមព្រែក អចលនទ្រព្យ និងការវិនិយោគផ្សេងៗ ដើម្បីបម្រើផលប្រយោជន៍ជាតិដ៏ធំធេង ជាពិសេសផ្នែកសេដ្ឋកិច្ចសង្គមនៅកម្ពុជា ទាំងនេះគឺសុទ្ធតែជាសមិទ្ធផលដ៏ធំធេងដែលកើតចេញពីការដឹកនាំប្រកបដោយគតិបណ្ឌិតនិងជាទីមោទនៈបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ជាពិសេសក្នុងការបន្តដឹកនាំស្ថាប័នព្រឹទ្ធសភា។

ឆ្លៀតក្នុងឱកាសដ៏នក្ខត្តឫក្សវិសេសវិសាលនៃពិធីចម្រើនជន្មាយុដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះផងដែរ យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ឫទ្ធិបារមីថែរក្សាប្រាង្គប្រាសាទអង្គរ ជាពិសេស ទេវតាថែរក្សា **ឆ្នាំរោង ឆស័ក** ព្រះនាម **មហោទរាទេវី** សូមតាមជួយថែរក្សា ការពារ អភិបាល ប្រោះព្រំនូវសព្ទសាធុការពរជ័យគ្រប់ប្រការជូនចំពោះ **សម្តេចតេជោប្រធានព្រឹទ្ធសភា** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ សូមសមប្រកបដោយពុទ្ធពរដ៏ឧត្តុង្គឧត្តមថ្លៃថ្លាទាំងប្រាំប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណ** កុំបីឃ្លៀងឃ្លាតឡើយ។

សូមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់និងគារវភក្តីដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំនិងភរិយា។

ថ្ងៃ សុក្រ ៦ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**